# ការអនុវត្ត ដែលបង្កគ្រោះថ្នាក់

ជារៀងរាល់ថ្ងៃ ក្មេងស្រី នៅជុំវិញពិភពលោក រាប់រយពាន់អ្នក បានរងគ្រោះទាំងលើរាងកាយ ឬផ្លូវចិត្ត ឬទាំងពីរ ដោយមានការដឹងឮ និងយល់ព្រមទាំងស្រុងពីក្រុមគ្រួសារ មិត្តភក្តិ និងសហគមន៍របស់ពួកគេ។ ផលប៉ះពាល់ដែលចាក់ស្រេះកើតឡើងទូទាំងសង្គម កំពុងបន្តជម្រុញគាំទ្រផ្នត់គំនិត និងវិសមភាពយេនឌ័រ។

វិសាលភាពនៃការអនុវត្តដែលបង្ករគ្រោះថ្នាក់គឺធំធេងណាស់ ប៉ុន្តែមានចំនុចពសំខាន់ៗ ស្ទើរតែត្រូវបានគេបដិសេធជាសកលថាជាការរំលោភសិទ្ធិមនុស្ស ដែលនៅបន្តរីករាលដាលយ៉ាងខ្លាំងដែលទាក់ទងនឹងការកាត់សិរីរាង្គភេទស្ត្រី អាពាហ៍ពិពាហ៍កុមារ និងទំនោរកូនប្រុស។

ការអនុវត្តទាំងនេះឆ្លងកាត់ព្រំដែន និងវប្បធម៌ជាច្រើន។ ការអនុវត្តខុសៗគ្នាទៅតាមលក្ខណៈជាក់លាក់នៃការប្រតិបត្តិរបស់ពួកគេ - ក្មេងស្រីត្រូវបានគេកាត់សរីរាង្គភេទរបស់នាងតាំងពីនៅក្មេង ឬនាងអាចបង្ខំចិត្តរៀបការនៅវ័យជំទង់ដើម្បី "ការពារខ្លួន" ពីការរំលោភសេពសន្ថវៈ ឬជាផ្នែកមួយនៃការជួញដូរ នាងអាចត្រូវបានរំលូត មុនពេលចាប់កំណើត ឬត្រូវបានគេបោះបង់ចោលរហូតដល់ស្លាប់។ ប៉ុន្តែការអនុវត្តទាំងនេះ គឺដូចគ្នាទៅនឹងសម័យដើម។ ផ្នត់គំនិតត្រូវបានចាក់ឫសនៅក្នុងវិសមភាពយេនឌ័រ និងបំណងប្រាថ្នាដើម្បីគ្រប់គ្រងផ្លូវភេទនិងការបន្តពូជរបស់ស្ត្រី។ ទោះបីជាផ្នត់គំនិតទាំងនោះបានធ្វើឱ្យអន្តរាយការបំផ្លិចបំផ្លាញដោយផ្ទាល់លើស្ត្រី និងក្មេងស្រី ហើយបង្កមហន្តរាយដល់ពិភពលោកនាពេលបច្ចុប្បន្ន និងអ្នកជំនាន់ក្រោយ ដែលផ្នត់គំនិតនេះអាចនៅតែបន្តកាន់តែធំឡើងជាងនេះទៅទៀត។ នៅពេលដែលសុខភាព ការអប់រំ និងសក្តានុពលរបស់ស្ត្រី និងក្មេងស្រីត្រូវបានថយចុះ ក៏មានផលប៉ះពាល់ដល់មនុស្សជាតិផងដែរ។

ប៉ុន្តែយើងមានអំណាចដើម្បីប្រឆាំងទៅនឹងកម្លាំងដែលបង្កអន្តរាយទាំងនេះ និងដើម្បីទទួលស្គាល់ថាពិភពលោកនេះជាកន្លែងដែលដែលស្ត្រី និងក្មេងស្រីគ្រប់រូបមានសេរីភាពក្នុងការរៀបចំចាត់ចែងអនាគតរបស់ខ្លួនដោយផ្ទាល់។

## ការរាតត្បាតជំងឺកូវីដ-១៩ មានហានិភ័យខ្ពស់

**របាយការណ៍ស្តីពីស្ថានភាពប្រជាជនលើពិភពលោកឆ្នាំ ២០២០ ត្រូវបានរៀបចំឡើងក្នុងដំណាក់កាលចាប់ផ្តើមនៃការរាតត្បាតជំងឺកូវីដ-១៩។**

ថ្ងៃនេះ របាយការណ៍ត្រូវបានចេញផ្សាយ គឺមានទិន្នន័យតិចតួចអំពីថាតើការរីករាលដាលនៃជំងឺរាតត្បាតកំពុងជះឥទ្ធិពលដល់ការអនុវត្តទាំងឡាយ ដែលបង្កគ្រោះថ្នាក់នៅជុំវិញពិភពលោកយ៉ាងដូចម្តេច ? ប៉ុន្តែមានភាពជាក់លាក់មួយចំនួនគឺ៖ ទីមួយ ការបង្អើតកម្មវិធីដែលបញ្ចប់អាពាហ៍ពិពាហ៍កុមារ និង FGM ដែលកំពុងប្រឈមមុខយ៉ាងធ្ងន់ធ្ងរនៃការពន្យារពេលអនុវត្តន៍។ ទីពីរ ការប៉ះពាល់ដល់សេដ្ឋកិច្ចដែលទាក់ទងនឹងជំងឺរាតត្បាតកំពុងបង្កើនភាពងាយរងគ្រោះដល់ក្មេងស្រី ទៅលើភាពអវិជ្ជមាននៃយន្តការដោះស្រាយរួមទាំងការអនុវត្តដែលបង្កគ្រោះថ្នាក់ទាំងនេះ។

UNFPA បានទទួលព័ត៌មានរួចមកហើយ និងកំពុងទទួលបានរបាយការណ៍ដំបូងនៃការកើនឡើងនៃ FGM និងអាពាហ៍ពិពាហ៍កុមារនៅក្នុងសហគមន៍មួយចំនួន។ ខណៈពេលដែលព័ត៌មានទាំងនេះមានលក្ខណៈបណ្តោះអាសន្ន ពួកគេគាំទ្រដល់ការវិភាគដែលធ្វើឡើងដោយ UNFPA Avenir Health សាកលវិទ្យាល័យ Johns Hopkins សហរដ្ឋអាមេរិក និងសាកលវិទ្យាល័យ Victoria អូស្ត្រាលី កាលពីខែមេសា ឆ្នាំ ២០២០ បានប៉ាន់ស្មានអំពីផលវិបាកដែលអាចកើតមានឡើងពីការរំខានដែលទាក់ទងនឹងជំងឺរាតត្បាតលើការអនុវត្តដែលបង្កគ្រោះថ្នាក់ទាំងពីរខាងលើនេះ។

ប្រសិនបើរោគរាតត្បាតបណ្តាលឱ្យមានការពន្យារពេលពីរឆ្នាំនៅក្នុងកម្មវិធីបង្ការ FGM អ្នកស្រាវជ្រាវគម្រោងបានព្យាករណ៍ថា ករណី FGM ចំនួន ២ លានករណី អាចនឹងកើតឡើងក្នុងទសវត្សរ៍ក្រោយ បើមិនដូច្នេះទេវាមិនអាចជៀសវាងបានឡើយ។

ប្រសិនបើជំងឺរាតត្បាតនេះត្រូវបានការពន្យារពេលរយៈពេលមួយឆ្នាំទៀតជាមធ្យម នោះការធ្វើអន្តរាគមដើម្បីបញ្ចប់អាពាហ៍ពិពាហ៍កុមារ តាមការប៉ាន់ប្រមាណទុកជាមុនថានឹងមានកុមារប្រមាណចំនួន ៧,៤ លាននាក់ទៀតត្រូវប្រឈមចំពោះបញ្ហានេះក្នុងទសវត្សរ៍ក្រោយ ដែលមិនអាចបញ្ចៀសបាន។ លើសពីនេះទៀតផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចដែលបណ្តាលមកពីការរីករាលដាលនៃជំងឺរាតត្បាតនេះត្រូវបានគេប៉ាន់ស្មានថា នឹងមានអាពាហ៍ពិពាហ៍កុមារ ប្រមាណជា ៥.៦ លាននាក់បន្ថែមទៀត ដែលនឹងកើតឡើងរវាងឆ្នាំ ២០២០ និង ២០៣០ ។ ផលប៉ះពាល់សរុបនៃជំងឺរាតត្បាតកូវីដ១៩ ត្រូវបានគេប៉ាន់ស្មានថានឹងធ្វើឱ្យអាពាហ៍ពិពាហ៍កុមារ កើនឡើងដល់ចំនួន ១៣ លាននាក់បន្ថែមទៀត។

UNFPA

ENSURING RIGHTS AND CHOICES FOR ALL

#AGAINSTMYWILL | WWW.UNFPA.ORG/SWOP

# ការប្រឆាំងនឹងឆន្ទៈ របស់ខ្ញុំ

**ប្រឆាំង** ការកាន់ទំនៀមទំលាប់ដែលប្រកបដោយគ្រោះថ្នាក់ដល់ស្ត្រី និងក្មេងស្រី និងការគំរាមកំហែងសមភាពយេនឌ័រ

UNFPA ស្ថានភាពប្រជាជនលើពិភពលោក ២០២០

នាង ជាទំនិញដែលត្រូវបានជួញដូរ
នាង ជាកម្មវត្ថុនៃសេចក្តីប៉ងប្រាថ្នា
នាង ជាបន្ទុកដែលត្រូវបានគេបោះបង់ចោល
នាង ជាប្រភពកម្លាំងពលកម្មឥតគិតថ្លៃ

**នាង ជាក្មេង ស្រី**

នេះគឺជាការពិតដ៏គួរឱ្យសង្វេគ៖
រាងកាយ ជីវិត និងអនាគតនាង ប៉ុន្តែមិនមែនជារបស់នាង
ប៉ុន្តែការផ្លាស់ប្តូរ ពិតជាអាចធ្វើទៅបាន

# ការកាត់សិរីរាង្គភេទស្ត្រី

## កាត់ កោរ ដេរ

ការកាត់សិរីរាង្គភេទស្ត្រី (FGM) គឺពាក់ព័ន្ធនឹងផ្នែកខ្លះ ឬទាំងស្រុងនៃប្រដាប់បន្តពូជទាំងផ្នែកខាងក្នុងនិងក្រៅរបស់ស្ត្រី ឬការរងរបួសផ្សេងទៀតចំពោះសរីរាង្គបន្តពូជស្ត្រី ដោយសារមូលហេតុមិនមែនជាកត្តាវេជ្ជសាស្ត្រ។

**វាកើតឡើងនៅគ្រប់តំបន់នៃពិភពលោកដែលជះឥទ្ធិពលដល់ស្ត្រី និងក្មេងស្រីចំនួន ២០០ លាននាក់ដែលកំពុងរស់នៅសព្វថ្ងៃ។**

ការរំលោភលើសិទ្ធិរបស់ស្ត្រី និងក្មេងស្រីចំពោះសិទ្ធិទទួលបានសុខភាព សុចរិតភាពនៃរាងកាយ និងដើម្បីរួចផុតពីការរើសអើង ការប្រព្រឹត្ត និងព្យាបាលដែលមិនមានគុណភាព ឬសាហាវព្រៃផ្សៃ ដែលវាអាចសម្លាប់ពួកគេបានផងដែរ។

ទោះយ៉ាងណាវានៅតែជាមូលដ្ឋានលើជំនឿខុសដែលថាជាការធ្វើឱ្យប្រសើរឡើងចំពោះការមានកូន ការបង្កើនអារម្មណ៍ស្រើបស្រាលសម្រាប់បុរស ការបង្ក្រាបផ្លូវភេទរបស់ស្ត្រីដោយអនុលោមទៅតាមការទាមទារផ្នែកសាសនា ឬការទទួលស្គាល់ដោយសហគមន៍។ វាត្រូវបានអនុវត្តដើម្បីថែរក្សាភាពបរិសុទ្ធ កិត្តិយស និងភាពស្អាតស្អំរបស់ក្មេងស្រី ដើម្បីធ្វើឱ្យពួកគេមានភាពទាក់ទាញកាន់តែច្រើនដើម្បីរៀបការ។

# អាពាហ៍ពិពាហ៍កុមារ

## ការសន្យា ការផ្តល់ឱ្យ ការជួញដូរ ត្រូវបានលក់

នៅពេលក្មេងស្រីរៀបការ ការសិក្សារបស់នាងជាធម្មតាត្រូវបានបញ្ចប់។ ការមានផ្ទៃពោះត្រូវបានចាប់ផ្តើម។ នាងងាយនឹងទទួលរងនូវការស្លាប់ទាក់ទងនឹងការមានផ្ទៃពោះ និងអំពើហិង្សាក្នុងគ្រួសារ។ ទ្វារទៅរកអនាគតដ៏ប្រសើរបានបិទ។

អាពាហ៍ពិពាហ៍កុមារត្រូវបានហាមឃាត់ជាសកល ប៉ុន្តែវាកើតឡើង ៣៣.០០០ ដងក្នុងមួយថ្ងៃ ជារៀងរាល់ថ្ងៃនៅជុំវិញពិភពលោក។

**តាមការប៉ាន់ស្មានមានក្មេងស្រី និងស្ត្រីប្រមាណជា ៦៥០ លាននាក់ ដែលកំពុងរស់នៅសព្វថ្ងៃបានរៀបការទាំងនៅជាកុមារ។**

ឪពុកម្តាយខ្លះបានរកហេតុផលដើម្បីឱ្យកូនស្រីឆាប់រៀបការ ដើម្បីធានាអនាគតសេដ្ឋកិច្ចរបស់ពួកគេ ឬពួកគេអាចចាត់ទុកកូនស្រីជាទំនិញសេដ្ឋកិច្ច និងជាវិធីដោះស្រាយបំណុល ឬជម្លោះនៅក្នុងគ្រួសារ។ ឪពុកម្តាយខ្លះជឿថាការឆាប់រៀបអាពាហ៍ពិពាហ៍នឹងការពារកូនស្រីរបស់ពួកគេពីអំពើហឹង្សាផ្លូវភេទដោយបែងចែកការទទួលខុសត្រូវចំពោះសុវត្ថិភាពកូនស្រីរបស់ពួកគេទៅប្តី និងគ្រួសារខាងប្រុស។ ការពិតដែលថាប្តីរបស់នាងអាចជាប្រភពនៃអំពើហិង្សាផ្លូវភេទដែលកម្រត្រូវបានគេពិចារណា។ គ្រួសារកាន់តែងាកទៅរកការរៀបចំអាពាហ៍ពិពាហ៍របស់កូនៗ នៅពេលមានវិបត្តិនិងការផ្លាស់ទីលំនៅ។

ប៉ុន្តែមូលដ្ឋានគ្រឹះនៃទំនៀមទំលាប់នេះគឺជាធម្មតាមានបំណងដើម្បីរក្សាព្រហ្មចារីយ៍របស់ក្មេងស្រីសម្រាប់ប្តីរបស់នាងមិនថាសូម្បីតែរាងកាយរបស់នាងជាវត្ថុកម្មសិទ្ធិ និងការប្រើប្រាស់របស់ប្តីទាំងស្រុង។

# ទំនោរកូនប្រុស

## មិនចង់បាន មិនពេញចិត្ត រំលូតចោល

នៅពេលក្មេងប្រុសមានតម្លៃខ្ពស់ជាងក្មេងស្រី សម្ពាធក្នុងការមានកូនប្រុសអាចខ្លាំងជាង។ គូស្វាមីភរិយាអាចខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីជៀសវាងការផ្តល់កំណើតដល់ក្មេងស្រី (ការជ្រើសរើសភេទកូន) ឬពួកគេអាចខកខានមិនបានថែរក្សាសុខភាព និងសុខុមាលភាពរបស់កូនស្រី ដែលពួកគេពេញចិត្តកូនប្រុសជាង (ការជ្រើសរើសភេទក្រោយពេលសម្រាល)។

ទំនោរកូនប្រុសមិនមែនជារឿងថ្មីនោះទេ ប៉ុន្តែនិន្នាការនេះឆ្ពោះទៅរកគ្រួសារតូចៗដែលមានកូនតិច។ ស្ត្រីភាគច្រើនសព្វថ្ងៃមានកូនបីនាក់ ឬតិចជាងនេះ។ ចំនួនកូនតិចមានន័យថាមានឱកាសតិចតួចក្នុងការមានកូនប្រុស។ ប្រហែលមួយភាគបួននៃឪពុកម្តាយទាំងអស់ដែលមានកូនស្រីពីរនាក់អាចជ្រើសរើសរបៀបរួមភេទ ដើម្បីចៀសវាងទទួលបានកំណើតកូនទីបីជាកូនស្រីទៀត។

**សព្វថ្ងៃនេះមានការប៉ាន់ស្មានថាមានស្ត្រីជាង ១៤០ លាននាក់កំពុងបាត់ខ្លួន ដោយសារផលវិបាកនៃទំនោរការចង់បានកូនប្រុស។**

ការអនុវត្តនេះអាចបណ្តាលឱ្យមានការបង្ខំ ឬរំលូតកូនដោយបង្ខំចំពោះស្ត្រីមានផ្ទៃពោះ។ ការបោះបង់ចោលឬការមិនរាប់បញ្ចូលស្ត្រីដែលផ្តល់កំណើតដល់ក្មេងស្រី ការខ្វះខាតអាហារូបត្ថម្ភ ការអប់រំមិនគ្រប់គ្រាន់ និងភាពអសកម្មចំពោះក្មេងស្រី។

នៅប្រទេសមួយចំនួន ទំនោរចង់បានកូនប្រុសបានបង្ខូចទ្រង់ទ្រាយសមាមាត្រភេទរបស់ប្រជាជនទាំងមូលដែលធ្វើឱ្យបុរសគ្មានដៃគូ ហើយធ្វើឱ្យអំពើហិង្សាប្រឆាំងយេនឌ័រកាន់តែធ្ងន់ធ្ងរឡើង។

## ការប្រឆាំងកំពុងកសាង

សហគមន៍អន្តរជាតិយល់ស្របជាខ្លាំងចំពោះការអនុវត្តដែលបង្កអន្តរាយទាំងនេះ គឺមិនអាចអត់អោនបានឡើយ។ សន្ធិសញ្ញាអន្តរជាតិជាងច្រើនទសវត្សរ៍ និងឧបករណ៍ដទៃទៀតបានអំពាវនាវឱ្យរដ្ឋាភិបាល សហគមន៍ និងបុគ្គលទាំងឡាយឱ្យបញ្ឈប់សកម្មភាពដែលបង្កគ្រោះថ្នាក់របស់ពួកគេ។

ជំនោរកំពុងប្រែទៅហើយដោយមានបុគ្គលកាន់តែច្រើនឡើងៗ បានរៀនអំពីគ្រោះថ្នាក់ដែលបណ្តាលមកពីការអនុវត្តទាំងនោះ។ ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះនៅក្នុងប្រទេសដែលមានអត្រាប្រេវ៉ាឡង់ FGM ខ្ពស់សមាមាត្រក្មេងស្រី និងស្ត្រីដែលចង់ឱ្យការអនុវត្តបញ្ឈប់ទ្វេដង។ ភស្តុតាងពីជុំវិញពិភពលោកបង្ហាញថា នៅពេលដែលក្មេងស្រីត្រូវបានផ្តល់អំណាចធ្វើឱ្យពួកគេមានជម្រើសព័ត៌មានជាច្រើនអំពីអាពាហ៍ពិពាហ៍ ដែលពួកគេអាចសម្រេចចិត្តនៅពេលក្រោយ។ នៅទូទាំងពិភពលោក សារអំពីសិទ្ធិមនុស្ស ការពង្រឹងសិទ្ធិអំណាចរបស់ក្មេងស្រី និងសមភាពយេនឌ័រកំពុងជំរុញឱ្យឪពុកម្តាយជឿជាក់ថាពួកគេនឹងរក្សាកូនស្រីរបស់ពួកគេឱ្យបន្តសិក្សានៅសាលារៀន។

ប៉ុន្តែវឌ្ឍនភាពនេះមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ដោយសារតែកំណើនប្រជាជនចំនួនក្មេងស្រីដែលរងគ្រោះថ្នាក់កំពុងកើនឡើង។ ហើយដំណោះស្រាយដែលមានប្រសិទ្ធិភាពបំផុតចំពោះការអនុវត្តដែលបង្កគ្រោះថ្នាក់ទាំងនេះ គឺការលើកស្ទួយតម្លៃរបស់ក្មេងស្រី និងការធានាឱ្យបាននូវសមភាពយេនឌ័រ។

## ផ្លូវឆ្ពោះទៅមុខ

មានជំហានច្បាស់លាស់ដែលប្រទេស និងសហគមន៍ទូទៅអាចអនុវត្តដើម្បីបញ្ចប់ការអនុវត្តដែលបង្កគ្រោះថ្នាក់។ ច្បាប់ហាមឃាត់ការអនុវត្តដែលបង្កគ្រោះថ្នាក់គឺជាវិធានការសំខាន់មួយ ប៉ុន្តែវាគ្រាន់តែជាចំណុចចាប់ផ្តើមប៉ុណ្ណោះ។

ការចូលរួមរបស់សហគមន៍ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតអាចជួយការពារការអនុវត្តដែលបង្កគ្រោះថ្នាក់ពីសម្រោលដែលកំពុងបន្តពីអតីតកាល។ ផែនការសកម្មភាពជាតិអាចប្រមូលផ្តុំសហគមន៍ អ្នកដឹកនាំក្នុងតំបន់ និងមេដឹកនាំសាសនា និងអ្នកផ្តល់សេវាកម្មនានាដោយធានាឱ្យបានការគាំទ្រ និងការចូលរួមពេញលេញ។

ហើយត្រូវតែមានការខិតខំដើម្បីផ្លាស់ប្តូរផ្នត់គំនិតទាំងនោះ។ កម្មវិធីដើម្បីផ្លាស់ប្តូរបទដ្ឋានសង្គមអាចនិងមានប្រសិទ្ធិភាពក្នុងការលុបបំបាត់ការអនុវត្តដែលបង្កគ្រោះថ្នាក់ ប៉ុន្តែពួកគេមិនត្រូវផ្តោតអារម្មណ៍តែលើការអនុវត្តទាំងនោះទេ។ ផ្ទុយទៅវិញពួកគេគួរតែដោះស្រាយបញ្ហាឱ្យកាន់តែទូលំទូលាយ ទាំងអ្នកដែលកំពុងដើរតួនាទីរួមបញ្ចូលទាំងតួនាទីថ្នាក់ក្រោមដែលទទួលបន្ទុកស្ត្រី និងក្មេងស្រី សិទ្ធិមនុស្ស និងរបៀបលើកកម្ពស់ឋានៈក្នុងសង្គម និងការទទួលបានឱកាសរបស់ស្ត្រី និងក្មេងស្រី។

រដ្ឋាភិបាលមានការទទួលខុសត្រូវដ៏សំខាន់មួយ៖ ប្រទេសនានាអាចផ្តល់អំណាចដល់ស្ថាប័នជាតិរបស់ស្ត្រីដោយអនុវត្តយន្តការអភិបាលកិច្ច ដូចជាក្រសួងកិច្ចការនារី និងក្រុមការងារបង្គោលទទួលបន្ទុកយេនឌ័រ និងការងារឆ្ពោះទៅរកការលុបចោលច្បាប់រើសអើង។ សុខភាពសាធារណៈ ការអប់រំ និងស្ថាប័នដទៃទៀតក៏មានតួនាទីផងដែរ។

ប៉ុន្តែមិនមាន "គ្រាប់កាំភ្លើងវេទមន្ត" នោះទេ។ យើងត្រូវពន្លឿនកិច្ចខិតខំប្រឹងប្រែង បង្កើនការវិនិយោគរបស់យើង និងបំពេញការប្តេជ្ញាចិត្តរបស់យើង។ យើងមិនអាចបញ្ឈប់បានទេរហូតដល់សិទ្ធិ ជម្រើស និងរាងកាយរបស់ក្មេងស្រីទាំងអស់ជារបស់ពួកគេយ៉ាងពេញលេញ។